# ដំណាំត្រសក់ចំណារ

## I. ការជ្រើសរើសពូជ:

គេប្រើប្រាស់ពូជ ២ប្រភេទគឺពូជនាំចូលដោយក្រុមហ៊ុនក្រៅប្រទេស និង ពូជប្រពៃណីដែលគេសន្សំទុកពីមួយឆ្នាំទៅមួយឆ្នាំច្រើនជំនាន់មកហើយ ។

១. ពូជនាំចូលឬពូជក្រុមហ៊ុន:

- ពូជស្ថានីយ៍ក្បាលកោះ KK1
- ពូជនៅទីផ្សារមកពី អ៊ីស្តវើស៊ីដ និង ពូជជាតៃមកពីប្រទេសថៃ

២. ពូជប្រពៃណីឬពូជក្នុងស្រុក:

ពូជនេះមានអាយុកាលលូតលាស់ខ្លី ដងដើមលូតលាស់យឺតកំពស់ដើមទាបមានដើមតូចស្លឹកល្អិតៗ ផ្លែមានច្រើនសណ្ឋានសាច់ជ្រាយទាន់ឆាប់ប្រែពណ៌ពីបៃតងទៅលឿងក្រោយពេលប្រមូលផលវាមានគ្រាប់ច្រើនសាច់ស្តើងសំបកស្តើង ប៉ុន្តែវាឆាប់ទទួលបានផលក្នុងករណីគ្រាប់ពូជទុកលើសពី ៥ខែឡើងទៅ ។






ពូជក្នុងស្រុក ពូជក្ងូនកាត់

## II. វិធីសាស្ត្រដាំដុះត្រសក់

ដើម្បីទទួលបានទិន្នផលល្អ អ្នកដាំដុះត្រូវយល់ដឹងនូវបទពិសោធន៍ល្អៗជាច្រើនដូចជា:

### ១. ការរៀបចំដី និងរង

ដីដែលដាំត្រសក់ពីរដូវមុនមិនត្រូវយកមកដាំត្រសក់ឡើយ ដំបូងត្រូវប្រមូលយកស្មៅចេញអោយស្អាត ភ្ជួរដីហាលអោយបានច្រើនដង និងច្រើនថ្ងៃមុននឹងលើករងសំរាប់ដាំ ។ របៀបលើករងត្រូវលើករងតាមទិសទឹកហូរនៅរដូវវស្សាកំពស់រងជាមធ្យម ២៥-៣0សម ទទឹងរង ១ម ប្រវែង ១០-១៥ម ក្រោយមកយកជីកុំប៉ុស្ត ឬ ជីលាមកសត្វចំនួន ២-៣ បង្គីជី ១៥-១៥-១៥ ទំងន់ ១០0ក្រាម ជី 0-0-៤៦ ទំងន់ ១០0ក្រាម ជីទាំង៣មុខនេះទៅបាចលើផ្ទៃមួយរង ហើយជ្រុំលប់ជីនោះទៅក្នុងដីក្បៀររងអោយស្មើបង្ហាប់គែមរងអោយហាប់ទើបគ្របកៅស៊ូលើរង និងចោះរន្ធសំរាប់ដាំតាមន្លោះជួរ និង គុម្ព ៦0សម × ៤0សម ។

## ២. របៀបដាំត្រសក់



ការគ្របរងសំរាប់ដាំ




ថ្នាំផ្សិតសំរាប់លាយគ្រាប់ពូជមុនដាំ

មុននឹងដាំគេត្រូវយកគ្រាប់ពូជមកហាលថ្ងៃអោយក្តៅ បន្ទាប់មកយកទៅដាក់ត្រាំទឹកធម្មតារយៈពេល៦-១០ម៉ោង រួចយកគ្រាប់ទៅផ្អាប់ដោយខ្ចប់នឹងក្រណាក់ស្អាតសើមដាក់ទុកមួយយប់ក្នុងធុងទឹកកកបិទជិត ។

ក្រោយពីពិនិត្យឃើញគ្រាប់ត្រសក់ដុះពន្លកបន្តិចៗ គេយកថ្នាំការពារជំងឺផ្សិតប្រភេទខុបភើហាយដ្រុកសាយចំនួនមួយស្លាបព្រាបាយទៅលាយជាមួយគ្រាប់ត្រសក់ចំនួនប្រហែល ២ កំប៉ុងទឹកដោះគោ ទើបយកគ្រាប់ទៅដាំ ។

របៀបដាំដាក់គ្រាប់ត្រសក់នៅតាមរន្ធដែលចោះចំនួន៣គ្រាប់ក្នុងមួយគុម្ពក្នុងជំរៅ២-៣សមបន្ទាប់មកយកផេះអង្កាមដែលត្រាំទឹកអោយសាបមកគ្របពីលើគ្រាប់ត្រសក់ ហើយស្រោចទឹកអោយជោគភ្លាម ។

## III. ការថែទាំដំណាំត្រសក់

បន្ទាប់ពីពេលដាំដុះត្រសក់រហូតដល់ពេលប្រមូលផលគេត្រូវដឹងបញ្ហាសំរាប់ទប់ស្កាត់ដូចជា ៖

### ១. ការស្រោចទឹក

ត្រសក់ជាប្រភេទដំណាំត្រូវការទឹករាល់ថ្ងៃ ប៉ុន្តែវាមិនទាមទានូវភាពជោគជាំខ្លាំងទេ វានឹងបណ្តាលអោយត្រសក់កើតជំងឺលឿងស្លឹក ដូចនេះប្រសិនបើគ្មានភ្លៀវគេត្រូវស្រោចត្រសក់រាល់ថ្ងៃមួយថ្ងៃ១-២ដង ប៉ុន្តែបើមានភ្លៀងត្រូវបង្ហូរទឹកដក់នោះចេញអោយអស់ពីបាតរងភ្លាមៗ ។ត្រសក់ត្រូវការទឹកខ្លាំងក្នុងវគ្គចេញផ្កាកង្វះទឹកក្នុងវគ្គនេះធ្វើអោយផ្កាត្រសក់ជ្រុះច្រើន ។

### ២. ការដកស្មៅ និងបន្ថែមជី

ក្រោយពីមានស្មៅដុះតាមចន្លោះរង ឬតាមរន្ធគុម្ព ត្រូវដកស្មៅចេញអោយស្អាតគ្រប់ដំណាក់កាលនៃការលូតលាស់របស់ត្រសក់ ។ ចំពោះការដាក់ជីបំប៉នបន្ថែមត្រូវចែកចេញជា៣វគ្គធំៗ គឺ:

- វគ្គលូតលាស់ក្រោយពីដាំបាន ១០-១៥ថ្ងៃត្រសក់មានស្លឹកចំនួន២-៣ គេត្រូវស្រោចជីអ៊ុយរ៉េបំប៉នបន្តិចៗ គឺជីមួយស្លាបព្រាបាយលាយទឹកមួយ ធុង ១៥-១៨លីត្រ ស្រោចចំគុម្ពត្រសក់ ។ បន្ទាប់មកទៀតចន្លោះពី ១៥-២០ថ្ងៃ ត្រូវស្រោចម្តងទៀត ។

- វគ្គចេញផ្កា ក្រោយពីត្រសក់ចេញផ្កាក្រពុំៗ គេត្រូវបន្ថែមជីប្រភេទ ១៥-១៥-១៥ មួយរងចំនួន ១៥០ក្រាម ដោយបោះចូលក្រោមកៅស៊ូតាមចន្លោះគុម្ព ។

- វគ្គប្រមូលផល ក្រោយពីត្រសក់បេះបាន ១-២លើកត្រូវយកជីអ៊ុយរ៉េចំនួន ៥០ក្រាម ជី ១៥-១៥-១៥ ចំនួន ៥០ក្រាម លាយបញ្ចូលគ្នា ហើយបោះចូលក្រោមកៅស៊ូតាមចន្លោះជួរ ។

### ៣. ការដោតចំណារ

នៅពេលរៀបចំដាំត្រសក់ គេត្រូវត្រៀមនូវចំណាររមែកឈើទុកជាមុន (មែកឈើស្ងួតៗ) នៅពេលត្រសក់មានស្លឹកចំនួន ៣-៤ សន្លឹក ចេញដៃសំរាប់តោងគេចាប់ផ្តើមយកមែកឈើនោះមកដោតអោយញឹកតាមគុម្ពនិមួយៗ ហើយចងគាបចំណារនោះអោយជាប់ដើម្បីអោយត្រសក់តោងឡើង ។





## IV. ការគ្រប់គ្រងជំងឺសត្វល្អិតចង្រៃ

ត្រសក់ជួបនូវបញ្ហាជំងឺនិងសត្វល្អិតចង្រៃ ច្រើនប្រភេទចាប់ពីវាដុះពន្លករហូតដល់វគ្គប្រមូលផលរួមមាន ៖

### ១. អំពីជំងឺសំខាន់ៗ និងការគ្រប់គ្រង

ជំងឺដែលជួបប្រទះមានក្រុមបង្កឡើងដោយ មេរោគផ្សិត និងវីរុសដែលចំលងដោយកត្តាជាច្រើនៈ

- ជំងឺផ្សិត មេរោគផ្សិតច្រើនប្រភេទហើយកើតលើ ឬស លើគល់ លើស្លឹក លើផ្កា។ កើតលើឬសហៅថាជំងឺពុកឬស កើតលើគល់ លើស្លឹកហៅថាជំងឺស្លឹកម្សៅ និងមួយទៀតហៅថាជំងឺទុំស្លឹក ។



**ជំងឺទុំស្លឹក**



**ផ្លែបានពីដើមរួញ**

ដើម្បីទុបទល់នឹងជំងឺនេះ គេប្រើថ្នាំការពារជំងឺផ្សិតប្រភេទកាប់តាំង (Captin) ឬហៅបានម្យ៉ាងទៀតថា អកតូសាយ (Orthocide) មកលាយទឹកបាញ់អោយបានញឹកញាប់ ៥-៧ថ្ងៃម្តងៗ ។

- ជំងឺបង្កឡើងដោយវីរុស ភាគច្រើនលេចចេញក្នុងវគ្គចេញផ្កា ប៉ុន្តែមេរោគវាចូលទៅក្នុងដើមត្រសក់ចាប់តាំងពីត្រសក់ដុះដំបូង វាចំលងដោយក្រុមសត្វល្អិតជាភ្នាក់ងារមាន ចៃ មមាច មមង់ រុយស និងពីងពាងក្រហមជាអ្នកបង្កអោយកើតជំងឺរួញ ហៅថាមូសាអ៊ិចវីរុស នៅពេលមានជំងឺនេះកើតឡើងត្រូវដកដើមចេញអនុវត្តវិធានការកំចាត់សត្វទាំងនេះចាប់ពីត្រសក់ដុះមុនជំងឺកើត ។

២. ***<u>សត្វល្អិតចង្រៃសំខាន់ៗ</u>***

សត្វល្អិតសំខាន់មាន៣ប្រភេទដែលតែងស៊ីបំផ្លាញ ស្លឹក ដើម ផ្កា និងផ្លែដូចជា ៖

- អណ្តើតមាសកវែង ពណ៌លឿងតែងស៊ីបំផ្លាញស្លឹកដំបូងនៃត្រសក់ (ស្លឹក កូទីឡេដុង) ក្រៅពីនោះទៀតវាស៊ីស្លឹកពិតដំបូង និងស៊ីផ្កាឈ្មោលផ្កាញី ។ គេយកថ្នាំប្រភេទហ្វូយ៉ាដង់ វី ហ្វូរ៉ង់ ឬវីបាមមករោយក្បែរៗគុម្ព ក្រោយពីស្រោចទឹកជោគរួចហើយ ។

- ដង្កូវកាត់គល់ ដង្កូវនេះញាស់ចេញពីដី ឬ ស្មៅក្នុងចំការពេលមុនដាំព្រោះមេអំបៅពងដាក់លើស្មៅពេលកូនដង្កូវញាស់ដំណាំក៏ដុះក្លាយជាចំណីរបស់វា វាកាត់គល់ត្រសក់ស៊ីជាអាហារនៅពេលយប់ ពេលថ្ងៃលាក់ខ្លួនក្នុងដីជំរៅប្រមាណ ៤-៥ សម ចំងាយពីគល់ដំណាំ ១៨-២៥សម ។ វិធានការការពារ និងកំចាត់គឺរោយថ្នាំដូចអណ្តើតមាសដែរ ។

- ដង្កូវមូលស៊ីត្រួយ មេអំបៅដង្កូវនេះពងដាក់ ចំណុចកំពូងត្រួយត្រសក់ពេលវាញាស់វាចាប់ផ្តើមស៊ី ត្រួយត្រសក់ខ្ចីៗ វគ្គចេញផ្កាដង្កូវនេះ ស៊ីផ្កាត្រសក់រំខានដល់ការបន្តពូជ ។ វិធានការកំចាត់គឺបាញ់ថ្នាំពុលប្រភេទឌុយប៉ុង (Dupont) ចំនួនពីរស្លាបព្រាបាយលាយជាមួយថ្នាំមេរ៉ាំងហ្វូល ៣0សេសេ លាយទឹក ១៨ លីត្របាញ់ពេលព្រឹកមុនថ្ងៃរះជាការល្អ ។

## V. ***<u>ការប្រមូលផល</u>***

ត្រសក់ចំណារគេយកផ្លែខ្ចីៗ ធ្វើជាបន្លែសំរាប់បរិភោគ និងសំរាប់កែច្នៃធ្វើជាអាហារផ្សេងៗទៀត ។



គេអាចបេះផ្លែត្រសក់ខ្ចីៗ ដោយប្រើកន្ត្រៃកាត់ទងផ្លែនៅពេលផ្លែត្រសក់មានទំហំ ២,៥-៣ ស.ម មានជាប់ដោយម្សៅស្តើងៗលើផ្លែ ។ ការប្រមូលផលអាស្រ័យតាមប្រភេទពូជក្នុងនោះពូជស្រាលអាយុក្រោយដាំប្រមាណ ៣២-៣៨ ថ្ងៃ ពូជកណ្តាលរយៈពេល ៤៥-៥0ថ្ងៃ ក្រោយដាំ ហើយពូជធ្ងន់អាយុ ៥៥-៦0ថ្ងៃ ។ ពូជស្រាលទិន្នផល១0-១៥តោន/ហ.ត ពូជកណ្តាល ១៨-២0 ន/ហ.តពូជធ្ងន់ ២២-២៤ តោន/ហ.ត ។